Australian Government
Department of Education, Skills and Employment

# COVID-19៖ អន្តរកាលចំពោះប្រាក់ឧបត្ថម្ភ ថែទាំកុមារ

កញ្ចប់ជួយសម្រាលដល់ការអប់រំកុមារមានអាយុមិនទាន់គ្រប់ចូលរៀន និងការថែទាំ (កញ្ចប់ជួយសម្រាល) ត្រូវបាន ពន្យារពេលរហូតដល់ថ្ងៃទី 12 ខែកក្កដា ឆ្នាំ 2020 ដើម្បីបន្តរក្សាឱ្យសេវាកម្មនានាអាចអនុវត្តបាន និងដើម្បីផ្តល់ការ ថែទាំគ្រួសាររបស់បុគ្គលិកសំខាន់ៗ និងកុមារងាយរងគ្រោះ។

ប្រាក់ឧបត្ថម្ភថែទាំកុមារ (CCS) និងប្រាក់ឧបត្ថម្ភថែទាំកុមារបន្ថែម (ACCS) នឹងត្រូវចាប់ផ្តើមឡើងវិញចាប់ពីថ្ងៃទី 13 ខែកក្កដា ឆ្នាំ 2020 ដោយមានការធ្វើតេស្តសកម្មភាពបន្ធូរបន្ថយសម្រាប់គ្រួសារនានា និងការបង់ប្រាក់អន្តរកាល ថ្មីសម្រាប់អ្នកផ្តល់សេវា។ នេះមានន័យថាចាប់ពីថ្ងៃទី 13 ខែកក្កដា ឆ្នាំ 2020 ឪពុកម្តាយនឹងត្រឡប់ទៅធ្វើសហរួមចំណែកទៅលើថ្លៃឈ្នួលថែទាំកូន។

គ្រួសារនានាដែលមានម៉ោងសកម្មភាពការងាររបស់ពួកគេបានកាត់បន្ថយដោយសារ COVID-19 នឹងត្រូវចូលប្រើប្រាស់ បាន 100 ម៉ោងនៃការថែទាំកុមារដែលមានប្រាក់ឧបត្ថម្ភ ក្នុងពីរសប្តាហ៍ម្តង រហូតដល់ថ្ងៃទី 4 ខែតុលា ឆ្នាំ 2020។ ដើម្បីចូលប្រើប្រាស់ប្រាក់ឧបត្ថម្ភ គ្រួសារទាំងនេះត្រូវតែធ្វើបច្ចុប្បន្នភាពកម្រិតសកម្មភាពរបស់ពួកគេជាមួយ Services Australia។  ការធ្វើបច្ចុប្បន្នភាពនេះអាចធ្វើបានតាមរយៈ គណនី Centrelink នៅលើអ៊ីនធឺណិត របស់ពួកគេតាមរយៈ myGov ឬ កម្មវិធីឧបករណ៍ចល័ត Express Plus Centrelink។

បន្ថែមពីនេះទៀត ការបង់ប្រាក់អន្តរកាលនឹងត្រូវបានធ្វើទៅឱ្យអ្នកផ្តល់សេវ ទាំងអស់ដែលបានអនុម័តយល់ព្រម ដែលបានទទួល CCS ពីមុន រួមមានសេវាកម្មនានាដែលបានធ្វើប្រតិបត្តិការដោយរដ្ឋ ដែនដី និងរដ្ឋាភិបាលតាម តំបន់។

ការបង់ប្រាក់គឺផ្អែកលើ 25 ភាគរយនៃចំណូលថ្លៃឈ្នួលរបស់អ្នកផ្តល់សេវា ឬកម្រិតអត្រាម៉ោងដែលមានស្រាប់មួយណា ក៏បានដែលទាបជាង នៅក្នុងរយៈពេលយោងដែលពាក់ព័ន្ធ។ នេះគឺជារយៈពេលយោងដូចគ្នាដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងកញ្ចប់ជួយសម្រាល (ពីរសប្តាហ៍ម្តងមុនថ្ងៃទី 2 ខែមីនា ឆ្នាំ 2020 និងសម្រាប់អ្នកផ្តល់សេវានានាដែលផ្តល់ការថែទាំពេលវិស្សមកាលក្នុងខណៈពេលរវាងវគ្គទី 3 និងវគ្គទី 4 នៅក្នុងឆ្នាំ 2019 ប៉ុណ្ណោះ)។

ការបង់ប្រាក់អន្តរកាលនឹងត្រូវបានធ្វើសម្រាប់រយៈពេលពីថ្ងៃទី 13 ខែកក្កដា ឆ្នាំ 2020 ដល់ថ្ងៃទី 27 ខែកញ្ញា ឆ្នាំ 2020។

ដើម្បីទទួលការបង់ប្រាក់អន្តរកាលនេះ អ្នកផ្តល់សេវាត្រូវតែបន្តជួលបុគ្គលិកដែលបានកំពុងធ្វើការ ឬកំពុងត្រូវបាន បង់ប្រាក់ JobKeeper នៅចុងបញ្ចប់នៃកញ្ចប់ជួយសម្រាល។ អ្នកផ្តល់សេវាក៏ត្រូវតែរក្សាថ្លៃឈ្នួលដែលបានគិតដូចគ្នានៅក្នុងរយៈពេលយោងដែលពាក់ព័ន្ធ (ដូចខាងលើ)។

JobKeeper នឹងបញ្ចប់ចាប់ពីថ្ងៃទី 20 ខែកក្កដា ឆ្នាំ 2020 សម្រាប់និយោជិតនៃអ្នកផ្តល់សេវា CCS ដែលបានអនុម័ត យល់ព្រម និងសម្រាប់អ្នកជំនួញទោល ដែលបើកប្រតិបត្តិការសេវាថែទាំកុមារ ឬកំពុងផ្តល់ការអប់រំសម្រាប់អ្នកផ្តល់ សេវាថែទាំកុមារ។

សម្រាប់ព័ត៌មានបន្ថែម សូមទៅកាន់ ទំព័របណ្ដាញ របស់ក្រសួងអប់រំ ជំនាញ និងការងារ ឬ សំណួរដែលសួរញឹកញាប់អំពីការអប់រំកុមារមានអាយុមិនទាន់គ្រប់ចូលរៀន និងការថែទាំ COVID-19។

អ្នកក៏អាច ជាវ ព្រឹត្តិប័ត្រអ៊ីមែលស្តីពីការអប់រំកុមារមានអាយុមិនទាន់គ្រប់ចូលរៀន និងការថែទាំ របស់ក្រសួងផងដែរ។